# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៧ សសរ

## សេចក្តីសម្រេច

ស្តីពី

ការបង្កើតក្រុមការងារផ្នែកច្បាប់ ទទួលបន្ទុកពិនិត្យសំណុំរឿងវិវាទ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

# ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារមួយ ដែលមានឈ្មោះថា **"ក្រុមការងារផ្នែកច្បាប់ ទទួលបន្ទុកពិនិត្យសំណុំរឿងវិវាទ"** ហៅកាត់ថា **"កចពស"** ដែលក្រុមការងារនេះត្រូវស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីជួយ **សម្តេចនាយករដ្ឋមន្ត្រី** ដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ។

**ប្រការ ២.-**

ក្រុមការងារ "**កចពស**" មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យ សិក្សា វិភាគលើសំណុំរឿងវិវាទទាំងឡាយណា ដែលមិនមែនជាសមត្ថកិច្ចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងលើកយោបល់គោរពជូន**សម្តេចនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យ និងសម្រេច ។
- ក្នុងករណីចាំបាច់ ក្រុមការងារនេះអាចចុះស្រាវជ្រាវអង្កេតរកព័ត៌មានលម្អិតបន្ថែម ដោយប្រើប្រាស់នូវមធ្យោបាយដែលជាសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ ។

**ប្រការ ៣.-**

សមាសភាពនៃក្រុមការងារនេះ រួមមាន ៖

| | | |
|---|---|---|
| - ឯកឧត្តម **អង្គ វង្ស វឌ្ឍានា** | រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ | ប្រធាន |
| - ឯកឧត្តម **ហ៊ី សោភា** | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| - ឯកឧត្តម **អ៊ិត រ៉ាឌី** | អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| - ឯកឧត្តម **ពេជ អង្គ** | សមាជិកបម្រុង ក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| - លោក **កើត រិទ្ធ** | តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| - លោក **ស៊ីង បញ្ញាវុឌ្ឍ** | ប្រធាននាយកដ្ឋានអយ្យការ ក្រសួងយុត្តិធម៌ | សមាជិក |
| - លោក **សួរ ចាន់ធី** | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ក្រសួងយុត្តិធម៌ | សមាជិក |

**ប្រការ ៤.-**

ក្រុមការងារ "**កចពស**" ប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ សម្រាប់ដំណើរការការងាររបស់ខ្លួន ។

www.pheakdeylaw.com

**ប្រការ ៥ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យប្រឹក្សានៃអគ្គចៅក្រម
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com